# ក្រសួងកសិកម្មអះអាងពីជោគជ័យជាប្រវត្តិសាស្ត្រមិនធ្លាប់ជួបពីមុនមក

*(រស្មីកម្ពុជា ៨ មេសា ២០០៩)*

ថ្លែងនៅក្នុងសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ ២០០៨-២០០៩ និងលើកទិសដៅសម្រាប់ឆ្នាំ ២០០៩-២០១០ កាលពីព្រឹកថ្ងៃទី ៧ មេសា លោកច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មបានបញ្ជាក់ថា កម្ពុជាបានដាំដុះស្រូវរដូវ វស្សាលើផ្ទៃដីសរុបជាង ២,២៥ លានហិកតា ដែលមានទិន្នផលជាមធ្យមចំនួន ២,៥៤ តោនក្នុង ១ ហិកតា ដោយទទួលបរិមាណផលសរុបប្រមាណជាង ១,៤៣ លានតោន។ សរុបទាំងរដូវវស្សា និងរដូវប្រាំងយើងអនុវត្តបានលើផ្ទៃដី សរុបជាង ២,៦១ លានហិកតា ដោយទទួលបរិមាណផលសរុបប្រមាណ ៧,១៥ លានតោនស្រូវ និងទិន្នផលជាមធ្យមប្រចាំឆ្នាំ ២,៧៤ តោនក្នុង ១ ហិកតា។ ដូច្នេះតុល្យភាពស្បៀងយើងនៅសល់ជាង ២,០១ លានតោន លើសឆ្នាំមុនជាង ០,៥៧ លានតោនស្រូវ និងខ្ពស់ជាងមធ្យមភាគ ១០ ឆ្នាំកន្លងមកជាង ២,២៨ លានតោនអង្ករ។

ក្នុងរបាយការណ៍របស់ក្រសួងក៏បាននិយាយផងដែរថា ផលិកម្មស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស) ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ខេត្តដែលធ្វើ ប.វ.ស ច្រើនជាងគេគឺខេត្តតាកែវ ដែលមានចំនួនជាង ៣៤ ពាន់គ្រួសារលើផ្ទៃដីជាង ២១ ពាន់ហិកតា។